## ការបំបាត់អាណានិគមនិយម (decolonization)

កាលពីមុន មានដែនដីជាច្រើន មិនមានឯករាជ្យ ឬមិនមែនជារដ្ឋអធិបតេយ្យ ដោយសារស្ថិតនៅក្រោមរបបអាណានិគមនិយម។ ក្រោយការបង្កើត អង្គការសហប្រជាជាតិក្តី អង្គការនេះ មិនមានសកម្មភាពច្រើនក្នុងការលុបបំបាត់អាណានិគមនិយមទេ ហើយរដ្ឋមួយចំនួន បានឯករាជ្យ ដោយគ្មានការជួយជ្រោមជ្រែងពីអង្គការនេះ។

ក្រោយមក តាមយន្តការបង្កើតតាមធម្មនុញ្ញអង្គការសហប្រជាជាតិ ដូចជា trusteeship system ដែលរដ្ឋទទួលខុសត្រូវ ព្រមដាក់ដោយស្ម័គ្រចិត្តនូវដែនដី និង មានគណៈកម្មាធិការទី៤ នៃមហាសន្និបាតអង្គការសហប្រជាជាតិ (UN General Assembly) បញ្ចូលគ្នានឹងគណៈកម្មាធិការនយោបាយពិសេស បានធ្វើការជាខ្លាំងផ្តោតលើការលុបបំបាត់អាណានិគមនិយម បាននាំនូវជោគជ័យជាច្រើន។ ប្រទេសដាក់អាណានិគម បានជំទាស់ក្នុងការដាក់ដែនដីមិនឯករាជ្យទាំងអស់ក្នុងប្រព័ន្ធ Trusteeship នេះ ទោះបីជាយ៉ាងនេះក្តី ការចែងដោយប្រយោលនូវកាតព្វកិច្ចរបស់រដ្ឋដាក់អាណានិគម ចំពោះដែនដីក្រោមការគ្រប់គ្រង ត្រូវបានដាក់បញ្ចូលក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ដោយជោគជ័យក្នុងមាត្រាចំនួន ២ ក្នុងនោះមានមាត្រា៧៣។

ក្នុងឆ្នាំ១៩៧៥ មានរដ្ឋជាសមាជិកអង្គការសហប្រជាជាតិចំនួន១៤៤ ដែលក្នុងនោះមាន ៧៧ ប្រទេស (Group of 77) ដែលជារដ្ឋទើបបានឯករាជ្យក្នុងតំបន់អាស៊ី និង អាហ្វ្រិក។ នេះនាំឲ្យមានសំឡេងនាំទៅដល់ការស្នើសើរើនូវវិធានសេដ្ឋកិច្ចថ្មី (New International Economic Order)។

រដ្ឋទាំង៧៧ នេះបានបង្កើតជាក្រុមមិនចូលបក្សសម្ព័ន្ធ (Non-Aligned Movement)។ ជោគជ័យនេះ មិនត្រូវបានបំភ្លេចនូវវត្តមាននៃសេចក្តីសម្រេចរបស់ UNGA ឆ្នាំ ១៩៦០ ស្តីពីការផ្តល់ឯករាជ្យដល់ប្រទេស និងប្រជាជនក្រោមរបបអាណានិគមនិយម (Declaration on Granting of Independence to Colonial Countries and People)។ សេចក្តីសម្រេចនេះ បានចែងលម្អិតសិទ្ធិស្វ័យសម្រេច (right to self-determination) ដែលមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិដែរ (Helmut Volger, A Concise Encyclopedia of the United Nations, 2nd Ed., 2010, pp. 67-69)។